## ឯកឧត្តម កាន ច័ន្ទមេត្តា រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ អបអរសាទរចំពោះអង្គការភីភលស្តូរី(PeopleStories) ដែលទទួលបានពានរង្វាន់ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកល្អបំផុត

**ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០២៤**

អង្គការភីភលស្តូរី (PeopleStories) ដែលជាទីភ្នាក់ងារអភិវឌ្ឍន៍មួយប្រកបដោយសេចក្តីប្តេជ្ញាចិត្តក្នុងការលើកកម្ពស់ជីវិតរបស់កុមារនៅទីជនបទនៃប្រទេសកម្ពុជាតាមរយៈការអប់រំ បានទទួលពានរង្វាន់កិត្តិយសមួយបន្ថែមទៀតសម្រាប់កម្មវិធីសិក្សាបែបឌីជីថលប្រកបដោយនវានុវត្តន៍របស់ខ្លួន។ សាលារៀនឌីជីថលចល័តរបស់អង្គការភីភផលស្តូរី បានបង្កើននូវសមត្ថភាពក្នុងការគិតប្រកបដោយហេតុផលរបស់កុមារយ៉ាងខ្លាំងក្លាមែនទែន!

នៅល្ងាចថ្ងៃអង្គារ ទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០២៤នេះ អង្គការភីភលស្តូរី ត្រូវបានផ្តល់កិត្តិយសក្នុងការទទួលពានរង្វាន់គម្រោងសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកល្អបំផុតនៅក្នុងពិធីប្រកបដោយកិត្តិយសមួយ ដែលត្រូវបានរៀបចំឡើងដោយ ឡឺនអ៊ិច (LearnX)។ ឡឺនអ៊ិច(LearnX)គឺជាកម្មវិធីពានរង្វាន់អន្តរជាតិអូស្ត្រាលីដ៏ឈានមុខគេមួយ ដែលប្រារព្ធអបអរចំពោះឧត្តមភាព និងនវានុវត្តន៍ក្នុងការសិក្សា ការអភិវឌ្ឍ និងការគ្រប់គ្រងធនធានមនុស្ស។

លោកស្រី វិកថូរៀ មីឡូសសិហ្វស្គី (Victoria Miloschewsky) ដែលជាស្ថាបនិក និងជានាយកប្រតិបត្តិនៃអង្គការភីភលស្តូរី បានបង្ហាញនូវសេចក្តីដឹងគុណដោយបានថ្លែងថា ***“នាងខ្ញុំពិតជាមានកិត្តិយសខ្លាំងណាស់ ដោយបានទទួលរង្វាន់ដ៏ល្បីពី ឡឺនអ៊ិច(LearnX)។ វាបង្ហាញពីការលះបង់ និងការខិតខំប្រឹងប្រែងដែលក្រុមការងាររបស់យើងបានវិនិយោគទៅលើបដិវត្តន៍ការអប់រំតាមតំបន់ទីជនបទ ដោយប្រែក្លាយពី “ការប្រើប្រាស់ដីស & ការនិយាយ” ទៅជា “ ការបើក & ការចុចតាមកុំព្យូទ័រ” វិញ។ សាលារៀនឌីជីថលចល័តរបស់យើងបានបង្កើតនូវឱកាសសិក្សាតាមបែបឌីជីថលដ៏មានតម្លៃសម្រាប់កុមារកម្ពុជារាប់ពាន់នាក់ ដែលពួកគេភាគច្រើនទើបតែមានឱកាសទទួលបានបទពិសោធន៍សិក្សាបែបនេះជាលើកដំបូង” ។***

ឯកឧត្តម កាន ច័ន្ទមេត្តា រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍កម្ពុជា ពិតជាមានអារម្មណ៍រំភើបចំពោះសមិទ្ធិផលដ៏គួរឱ្យកត់សម្គាល់មួយនេះខ្លាំងណាស់ ។ លោកបានលើកឡើងថា ***“ស្របពេលដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងខិតខំធ្វើការផ្សព្វផ្សាយអំពីសារៈសំខាន់នៃឌីជីថលភាវូបនីយកម្ម ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយដោយបានមើលឃើញពីការផ្លាស់ប្តូរប្រកបដោយឥទ្ធិពលវិជ្ជមាន ដែលលោកស្រី វិកថូរៀ (Victoria) និងក្រុមការងារ ភីភលស្តូរី របស់គាត់ កំពុងតែសម្រេចបានក្នុងការនាំយកបច្ចេកវិទ្យាប្រើក្នុងវិស័យអប់រំ (EdTech) ជូនដល់ក្មេងៗជំនាន់ក្រោយរបស់យើង ។ ពិតជាធ្វើបានប្រសើរខ្លាំងណាស់!”***

សាលាឌីជីថលចល័តរបស់អង្គការភីភលស្តូរី ត្រូវបានបង្កើតចេញជារូបរាងតាមរយៈការបំប្លែងរ៉ឺម៉កតុក តុកចាស់មួយឲ្យទៅជាថ្នាក់រៀនចល័ត ដោយបំពាក់នូវឧបករណ៍សិក្សាបែបឌីជីថលដូចជាកុំព្យូទ័រយួរដៃជាដើម ។ ‘សាលារៀននៅលើកង់រ៉ឺម៉ក (school-on-wheels)’ មួយនេះ ធ្វើដំណើរទៅកាន់សហគមន៍តាមទីជនបទនានា ដែលជួយសម្របសម្រួលការរៀនតាមបែបឌីជីថលគ្រប់ពេលវេលា និងគ្រប់ទីកន្លែង ។

សាលរៀនឌីជីថលចល័ត (MDS) ផ្តល់នូវការរៀនបែបឌីជីថលប្រកបដោយគុណភាព រួមជាមួយនឹងសកម្មភាពផ្ទាល់រួមបញ្ចូលគ្នា រួមទាំងការអនុវត្តគម្រោងជាក្រុម ហ្គេមឌីជីថល និងការដោះប្រស្នា ដែលជួយពង្រឹងកម្មវិធីសិក្សារបស់រដ្ឋាភិបាលកម្ពុជាប្រកបដោយប្រសិទ្ធភាព និងផ្តល់ឱកាសដ៏ល្អបំផុតដល់កុមារដើម្បីរៀន និងបញ្ចប់ការសិក្សារបស់ពួកគេ។

លោក អនដ្រៀ ហ្វីសហ្សឺ (Andreas Fischer) ប្រធានក្រុមអ្នករចនាកម្មវិធីសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក និងអ្នកស្ម័គ្រចិត្តរបស់អង្គការភីភលស្តូរី បានបន្ថែមថា ***"វគ្គសិក្សាស្តីពីការគិតបែបស៊ីជម្រៅ (Critical Thinking Course) របស់យើងកំពុងបោះជំហានយ៉ាងសំខាន់ ដោយផ្តល់សិទ្ធិអំណាចដល់៩៧%នៃកុមារដែលបានចូលរៀនវគ្គនេះក្នុងការបង្កើនសមត្ថភាពរបស់ពួកគេទៅលើការគិតដោយហេតុផល និងធ្វើឱ្យ៩៦% បំពេញបានតាមស្តង់ដារគិតដោយហេតុផលបន្ទាប់ពីពួកគេបានបញ្ចប់វគ្គសិក្សា។ នោះគឺពិតជាបានផ្តល់នូវផលជះយ៉ាងខ្លាំងក្លា!”***

ចាប់តាំងពីបានបង្កើតឡើងក្នុងឆ្នាំ ២០២២ មក សាលារៀនឌីជីថលចល័តរបស់អង្គការភីភលស្តូរី បានបំពេញការសិក្សាជាង ៣០.០០០ម៉ោងដោយជោគជ័យដល់កុមារជាង ១.២០០ នាក់នៅតាមភូមិនានាទូទាំងប្រទេសកម្ពុជា។ កុមារទាំងនេះ រួមជាមួយនឹងគ្រូបង្រៀនរបស់ពួកគេជាច្រើននាក់មិនដែលបានប្រើកុំព្យូទ័រយួរដៃ ឬក៏មានបទពិសោធន៍រៀនតាមបែបឌីជីថលពីមុនមកនោះទេ។

Copyright © 2024 PeopleStories Charity Limited, All rights reserved.

លោកស្រី វិកថូរៀ មីឡូសសិហ្វស្គី (Victoria Miloschewsky) មានប្រសាសន៍ថា *“សាលារៀនឌីជីថលចល័តបានបញ្ជាក់ឲ្យឃើញថាគោលគំនិតនៃការប្រើប្រាស់បទពិសោធន៍សិក្សាឌីជីថលតាមគេហទំព័រប្រកបដោយជំនាញវិជ្ជាជីវៈនៅទីកន្លែងដាច់ស្រយាលដោយមិនត្រូវការអ៊ីនធឺណិតអាចអនុវត្តទៅបាន។ ខ្ញុំពិតជាមានមោទនភាពក្នុងការនិយាយថា អង្គការភីភលស្តូរី (PeopleStories) គឺពិតជាបាននាំយកមកនូវសាលាឌីជីថលចល័តដំបូងគេទៅកាន់ភូមិជនបទនានាក្នុងប្រទេសកម្ពុជា!”*

អង្គការភីភលស្តូរី (PeopleStories) បាននិងកំពុងផ្តល់អាហារូបករណ៍ អគារសិក្សា និងសម្ភារៈបរិក្ខារ កង់ កម្មវិធីបំណិនជីវិត និងកម្មវិធីសិក្សាតាមបែបឌីជីថលដល់សាលារៀន និងកុមារនៅតាមជនបទនៃប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ ២០១៧ មកម្ល៉េះ។ ដើម្បីស្វែងយល់បន្ថែម និងចូលរួមបរិច្ចាគចំពោះបុព្វហេតុដ៏មានតម្លៃបំផុតនេះ សូមចូលទៅកាន់គេហទំព័រ www.PeopleStoriesCharity.org ។

**ចប់**

សេចក្តីប្រកាសព័ត៌មាននេះត្រូវបានចេញផ្សាយដោយអង្គការភីភលស្តូរី (PeopleStories Charity)

ទំនាក់ទំនង៖ លោកស្រី វិកថូរៀ មីឡូសសិហ្វស្គី (Victoria Miloschewsky)

អ៊ីម៉េល៖ Team@PeopleStoriesCharity.org

ទូរស័ព្ទ៖ +៦១២ ៨០០៣ ៨៣៥៣

គោលបំណងរបស់យើង៖ http://bit.ly/Purpose_of_PeopleStories

បរិច្ចាគ៖ https://bit.ly/Donate_PS2024

គេហទំព័រ៖ https://www.peoplestoriescharity.org/

**កំណត់ចំណាំសម្រាប់អ្នកកែសម្រួលអត្ថបទ៖**

**អំពីអង្គការភីភលស្តូរី (PeopleStories)៖**

• បេសកកម្មរបស់អង្គការភីភលស្តូរី (PeopleStories) គឺដើម្បីជួយកុមារដែលសក្តិសមនឹងជួយនៅតាមទីជនបទនៃប្រទេសកម្ពុជាឱ្យបានបញ្ចប់ការសិក្សា។

• បង្កើតឡើងក្នុងឆ្នាំ ២០១៧ និងទទួលបានការទទួលស្គាល់ជាអង្គការសប្បុរសធម៌នៅក្នុងទីក្រុងហុងកុង និងប្រទេសកម្ពុជា អង្គការនេះជួយដល់សាលារដ្ឋចំនួន ១៣សាលា តាមរយៈការផ្តល់អាហារូបករណ៍ កម្មវិធីសិក្សាបែបឌីជីថល ការសាងសង់អគារសិក្សា កម្មវិធីអក្ខរកម្ម និងអប់រំកាយ និងកីឡា។

• អ្នកអាចស្តាប់បន្ថែមអំពីគោលបំណងរបស់យើងនៅទីនេះ។

• ក្នុងឆ្នាំ ២០១៧ អង្គការបានផ្តល់អាហារូបករណ៍ចំនួន ២១ ដល់កុមារ។ ជាមួយនឹងកំណើនលូតលាស់ដោយពឹងលើធនធានខ្លួនឯងផ្ទាល់ យើងបានបង្កើនអាហារូបករណ៍ដល់កុមារចំនួន ២០០ នាក់ និងជួយគ្រួសាររបស់ពួកគេនៅឆ្នាំ ២០២៤ នេះ។

• អង្គការភីភលស្តូរី (PeopleStories) ត្រូវបានគាំទ្រដោយអ្នកស្ម័គ្រចិត្តធ្វើការពីចម្ងាយជាង ៣០ នាក់នៅជុំវិញពិភពលោក និងក្រុមការងារក្នុងស្រុកតូចមួយនៅក្នុងខេត្តសៀមរាប។

• យើងប្រកាន់ខ្ជាប់នូវគោលការណ៍ផ្តល់មូលនិធិរបស់យើង៖ "១០០%នៃការបរិច្ចាគគឺប្រើទៅជួយកុមារឱ្យបញ្ចប់ការសិក្សា។"

Copyright © 2024 PeopleStories Charity Limited, All rights reserved.